58/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៦៤

ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១១

សាលដីកា

លេខ: ២៨៣

ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោម:

| | | |
|---|---|---|
| ១-ឯកឧត្តម | [redacted] | ជាប្រធាន |
| ២-លោកស្រី | [redacted] | ជាចៅក្រម |
| ៣-លោក | [redacted] | ជាចៅក្រម |
| ៤-លោក | [redacted] | ជាចៅក្រម |
| ៥-លោក | [redacted] | ជាចៅក្រម |

ក្រឡាបញ្ជី

លោក [redacted]

តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ០៥ក្រVI "អ" ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៦៤ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១១ របស់តុលាការកំពូល។

<u>ពីបទ:</u> ផ្តល់សក្ខីភាពក្លែង និងក្លែងលិខិតឯកជន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា៥០ និងមាត្រា៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-ជនជាប់ចោទឈ្មោះ [redacted](ម្ចាស់បណ្តឹងសារទុក្ខ) ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរពាណិជ្ជករ ទីកន្លែងកំណើតភូមិអណ្តូង សង្កាត់គោករកា ខណ្ឌដង្កោ រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នភូមិអណ្តូង សង្កាត់គោករកា ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោ[redacted]" ប្រពន្ធឈ្មោ[redacted]កូនគ្មាន ទោសពីមុនគ្មាន។

មានមេធាវីលោកស្រី [redacted]



Scanned by CamScanner

58/4

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៦០ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ១៩៦ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ។

-កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៤ ឈ្មោះ [redacted] និងគូកន បានធ្វើកិច្ចសន្យាទិញនិងលក់ដីក្លែងក្លាយដោយបានក្លែងស្នាមមេដៃ និងក្លែងដាក់ឈ្មោះ [redacted] ជាបានលក់ដីនៅភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ មកឱ្យខ្លួនឈ្មោ [redacted] រួចយកលិខិតក្លែងនោះទៅប្តឹងតុលាការក្រុងភ្នំពេញ ដើម្បីឱ្យតុលាការសម្រេចប្រគល់ដីឱ្យខ្លួនធ្វើជាម្ចាស់កម្មសិទ្ធិស្របច្បាប់។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា: សម្រេចបញ្ជូនជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣៨ឆ្នាំ ទៅជំនុំជម្រះ និងលើកលែងចោទប្រកាន់គូកន។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២៨"ដ" ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេច៖

១-ផ្តន្ទាទោសឈ្មោះ [redacted] ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារសរុបកំណត់១ឆ្នាំ (មួយឆ្នាំ) និងពិន័យជាប្រាក់ចំនួន៥.០០០.០០០រៀល (ប្រាំលានរៀល) សំរាប់ដាក់ចូលក្នុងថវិការដ្ឋ ពីបទ: ក្លែងលិខិតឯកជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ១៩៩៣ និងថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងផ្តន្ទាទោសឈ្មោះ [redacted] ទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់១ឆ្នាំ (មួយឆ្នាំ) ពីបទ: ផ្តល់សក្ខីភាពក្លែង ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល សរុបកំណត់ចំនួន២ឆ្នាំ (ពីរឆ្នាំ) គិតបន្តពីសាលក្រមមុន។

២-បង្គាប់ឱ្យឈ្មោះ [redacted] បង់ប្រាក់ពិន័យចំនួន៥.០០០.០០០រៀល (ប្រាំលានរៀល) ដាក់ចូលក្នុងថវិការដ្ឋ ពីបទ: ក្លែងលិខិតឯកជន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ១៩៩៣ និងថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៣-បដិសេធចោលការសុំចាត់របៀបបង្វិលសំណុំរឿងនេះទៅអយ្យការ ដើម្បីចោទប្រកាន់លើគូកនរបស់មេធាវីតំណាង និងការពារសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី។

៤-ទុកសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារសំណងនៅពេលក្រោយ។

៥-សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។



Scanned by CamScanner

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៣២០ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២៨"ជ" ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ របស់ សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខ្វះមូលដ្ឋានគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ២៨ "ជ" ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០៥ "ក្រVIអ" ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច៖

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ២៨"ជ" ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល។

៣-បន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] តាមនីតិវិធីច្បាប់។

៤-សាលដីកានេះជំនុំជម្រះ នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១១ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ កំបាំងមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទ។

បើកសិទ្ធិឱ្យប្តឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ៥៤ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ០៥ "ក្រVIអ" ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា:

១-ទទួលបណ្តឹងសាទុក្ខដូចបញ្ជាក់ខាងលើ ដោយចាត់ទុកជាត្រឹមត្រូវតាមគតិច្បាប់។

២-បដិសេធសាលដីការបស់សាលាឧទ្ធរណ៍ទុកជាមោឃៈពេញទាំងមូល។

៣-បង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះឡើងវិញលើឈ្មោះ [redacted] ពីបទ ក្លែងលិខិតឯកជន។

-បានស្តាប់សវនាជាតិ និង ចំលើយបរវះអាងរបស់ជនជាប់ចោទឈ្មោះ [redacted] នាពេលសវនាការថា៖ មូលហេតុអ្វីបានជាអ្នកឯងប្តឹងសាទុក្ខ? ខ្លួនប្តឹងសាទុក្ខដោយសារតែតុលាការផ្តន្ទាទោស

ខ្លួនច្រើនពេក ការក្លែងលិខិតនេះគឺខ្លួនបានទិញដីពីឈ្មោះ [redacted] ខ្លួនមិនដឹងពីការក្លែងទេ។ [redacted] នេះជាអ្នកកណ្តាលក្នុងការលក់ ចំណែកខ្លួនអ្នកទិញមិនបានទាក់ទងជាមួយអ្នកលក់ដីផ្ទាល់ទេ។ ឯកសារទាំងអស់ឈ្មោះ [redacted] ជាអ្នកធ្វើ ឯប្រាក់ខ្លួនជាអ្នកប្រគល់ឱ្យឈ្មោះ [redacted] ទាំងអស់ជាង១០ម៉ឺនដុល្លា ក្រោយពីទិញហើយឆ្នាំ១៩៩៣ ខ្លួនបានចូលកាន់កាប់ដីព្រមទាំងបានចិញ្ចឹមត្រី, ចិញ្ចឹមទា លុះដល់ឆ្នាំ២០០៧ ទើបម្ចាស់ដីគេប្តឹងយកដីគេវិញ ដោយចោទខ្លួនថា ផ្តល់សក្ខីភាពក្លែងក្លាយ និងក្លែងលិខិតយកដីចំនួន១១ហិកតានោះ ក្រោយពីខ្លួនគ្រប់គ្រងហើយ ខ្លួនក៏បានដាក់ពាក្យបណ្តឹងទៅតុលាការក្រុងភ្នំពេញ ដើម្បីចេញសាលក្រមធ្វើប័ណ្ណកម្មសិទ្ធដាក់ឈ្មោះខ្លួន។ ដូច្នេះខ្លួន សុំបដិសេធបទផ្តល់សក្ខីភាពក្លែង ឯបទក្លែងលិខិតឯកជនខ្លួនសុខចិត្តទទួល។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា: ពុំមានយោបល់អ្វីបន្ថែមទៀតទេ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

<u>តុលាការកំពូល</u>

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៥៤ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ស្ថិតនៅក្នុងកំណត់ច្បាប់ ដែលតុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា ការដែលសាលាដំបូងរាជធានីភ្នំពេញក៏ដូចជាសាលាឧទ្ធរណ៍ផងដែរ ដែលសម្រេចផ្តន្ទាទោសឈ្មោះ [redacted] ពីបទ: សក្ខីភាពក្លែងក្លាយនោះ គឺជាការភ័ន្តច្រឡំ ពីព្រោះថា មាត្រា៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលដែលចែងអំពីបទល្មើសសក្ខីភាពក្លែងក្លាយ គឺសំដៅអនុវត្តទៅលើប្រធាននៃបទល្មើស គឺជាសាក្សី និងអ្នកជំនាញដែលបានបង្ហាញភស្តុតាង ឬហេតុផលណាដែលមិនពិតដល់តុលាការ ប៉ុន្តែករណីនេះចំពោះជនជាប់ចោទឈ្មោះ [redacted] ញ គឺជាភាគីនៅក្នុងរឿងក្តី។ ហេតុដូច្នេះ បញ្ញត្តិច្បាប់ខាងលើមិនអាចយកមកអនុវត្តធ្វើការចោទប្រកាន់លើឈ្មោះ [redacted] បានទេ។ ដូចនេះតាមមាត្រា៤៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលសម្រេចឱ្យជនជាប់ចោទឈ្មោ [redacted] ចផុតពីបទល្មើសក្លែងសក្ខីភាពក្លែងក្លាយ។ រីឯតុលាការអង្គសេចក្តីសម្រេចផ្តន្ទាទោសឈ្មោះ [redacted] ពីបទ ក្លែងលិខិតឯកជន នោះជាការត្រឹមត្រូវហើយ ប៉ុន្តែដោយនាពេលបច្ចុប្បន្នក្រមព្រហ្មទណ្ឌមានអានុភាពអនុវត្ត ហើយតាមបញ្ញត្តិមាត្រា៦២៧ នៃក្រមថ្មីនេះចែងអំពីទោស ចំពោះបទល្មើសក្លែងបន្លំឯកសារមានលក្ខណៈស្រាលជាងទោសដែលមានចែង



Scanned by CamScanner

ក្នុងបញ្ញត្តិមាត្រា៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដែលជាច្បាប់ចាស់នោះ។ ដូច្នេះ តាមស្មារតីនៃមាត្រា១០ នៃក្រមព្រហ្មទណ្ឌ តុលាការគប្បីយកបទបញ្ញត្តិនៃច្បាប់ថ្មី ដែលចែងអំពីទោសស្រាលជាងមកអនុវត្ត ដើម្បីជាផលប្រយោជន៍របស់ជនជាប់ចោទ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ០៥ "ក្រVIអ" ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះខុសខ្លះត្រូវខ្លះ។

ហេតុដូច្នេះ

សំរេចសេចក្តី

១-ទទួលផ្នែកខ្លះនៃបណ្តឹងសាទុក្ខលេខ៥៤ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ របស់ឈ្មោះ [redacted]

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ០៥ "ក្រVIអ" ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ទុកជាបានការលើកលែងតែសេចក្តីសំរេចត្រង់ចំណុចទី២ ដែលត្រូវបដិសេធចោល។

៣-សម្រេចឱ្យឈ្មោះ [redacted]រួចផុតពីបទ ផ្តល់សក្ខីភាពក្លែង ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៤-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៦៤ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១១ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះលើការផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ពីបទក្លែងលិខិតឯកជន។

៥-សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។

រាជធានីភ្នំពេញ ថ្ងៃទី 12 ខែ 5 ឆ្នាំ២០១៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី 12 ខែ 5 ឆ្នាំ២០១៣

ជ. ប្រធានតុលាការកំពូល

អនុប្រធាន

[redacted]



Scanned by CamScanner